ប្រាក់អាហារូបករណ៍បន្ថែមសម្រាប់សិស្សវិទ្យាល័យខេត្តកាណាហ្គាវ៉ា(ធម្មតា・ជាតិ/សាធារណៈ)

ប្រាក់ឧបត្ថម្ភដែលផ្តល់ជូនដោយមិនតម្រូវឱ្យសងវិញដើម្បីជួយរ៉ាប់រងការចំណាយលើការអប់រំក្រៅពីថ្លៃសិក្សាដូចជាថ្លៃសៀវភៅសិក្សានិងថ្លៃសម្ភារៈសិក្សាជាដើម។

លក្ខខណ្ឌនៃការទទួលបានប្រាក់ឧបត្ថម្ភនិងចំនួនទឹកប្រាក់ដែលត្រូវទទួល

ដើម្បីមានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភអ្នកត្រូវតែបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម គិតត្រឹមថ្ងៃទី1 ខែកក្កដា ឆ្នាំ2026។

(1) អាណាព្យាបាលត្រូវមានទីលំនៅនៅក្នុងខេត្តកាណាហ្គាវ៉ា។

- ប្រសិនបើលោកអ្នករស់នៅក្រៅខេត្តកាណាហ្គាវ៉ា សូមទាក់ទងសាកសួរទៅកាន់ការិយាល័យរដ្ឋបាលខេត្ត ឬរាជធានី (都道府県) ដែលលោកអ្នករស់នៅ។

(2) សិស្សកំពុងចុះឈ្មោះសិក្សានៅវិទ្យាល័យ (ឬសាលាប្រហាក់ប្រហែល)។

●សិស្សដែលស្ថិតក្នុងលក្ខខណ្ឌទទួលបានប្រាក់ឧបត្ថម្ភត្រូវតែកំពុងសិក្សានៅវិទ្យាល័យឬគ្រឹះស្ថានអប់រំដែលមានកម្រិតសមមូល។

«សិស្សវិទ្យាល័យជាដើម» សំដៅលើសិស្សដែលមានសិទ្ធិទទួលបានប្រាក់ជំនួយថ្លៃសិក្សា (就学支援金)
ប្រាក់ជំនួយការសិក្សាថ្មីសម្រាប់សិស្សវិទ្យាល័យជាដើម (高校生等・新修学支援金) ឬប្រាក់ជំនួយសម្រាប់ការចូលរៀនឡើងវិញ (学び直し支援金)។

(3) គ្រួសាររបស់លោកអ្នកស្ថិតក្នុងប្រភេទមួយខាងក្រោម។

ស្ថានភាពគ្រួសាររបស់លោកអ្នកត្រូវតែស្របតាមលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌដូចខាងក្រោម

ចំនួនទឹកប្រាក់ឧបត្ថម្ភប្រចាំឆ្នាំសម្រាប់សិស្សវិទ្យាល័យម្នាក់ៗដែលស្ថិតក្នុងក្រុមគោលដៅ

ប្រភេទគ្រួសារ	លក្ខខណ្ឌ	ពេញម៉ោង ក្រៅម៉ោង	ពីចម្ងាយ
①គ្រួសារដែលទទួលបានជំនួយសង្គម	កំពុងទទួលបានជំនួយសម្រាប់ការប្រកបរបរចិញ្ចឹមជីវិត គិតត្រឹមថ្ងៃទី១ ខែកក្កដា	32, 300 យ៉ែន	
②គ្រួសារដែលមិនជាប់ពន្ធប្រជាពលរដ្ឋក្នុងតំបន់	ចំនួនសរុបនៃពន្ធដែលគិតតាមប្រាក់ចំណូលរបស់អាណាព្យាបាលទាំងអស់ស្មើនឹង ០ យ៉ែន (មិនរាប់បញ្ចូលប្រភេទ ①)	143, 700 យ៉ែន	50, 500 យ៉ែន
③គ្រួសារដែលមានប្រាក់ចំណូលប្រចាំឆ្នាំប្រហែល 2,700,000–3,800,000 យ៉ែន	ចំនួនសរុបនៃពន្ធដែលគិតតាមប្រាក់ចំណូលរបស់អាណាព្យាបាលទាំងអស់តិចជាង 105,500 យ៉ែន (មិនរាប់បញ្ចូលប្រភេទ ① និង ②)	47, 900 យ៉ែន	16, 830 យ៉ែន
④គ្រួសារដែលមានប្រាក់ចំណូលប្រចាំឆ្នាំប្រហែល 3,800,000–4,900,000 យ៉ែន	ចំនួនសរុបនៃពន្ធដែលគិតតាមប្រាក់ចំណូល របស់អាណាព្យាបាលទាំងអស់តិចជាង182,500 យ៉ែន (មិនរាប់បញ្ចូលប្រភេទ ① ដល់ ③)	35, 930 យ៉ែន	12, 630 យ៉ែន

●ក្នុងករណីដែលមិនជាប់ពន្ធដោយសារមិនមានអាសយដ្ឋាននៅក្នុងប្រទេសជប៉ុនដូចជាករណីត្រូវបានបញ្ជូនទៅបំពេញការងារនៅក្រៅប្រទេសជាដើម នោះនឹងមិនមានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភសម្រាប់ការសិក្សាឡើយ។

○ប្រសិនបើលោកអ្នកមិនស្ថិតក្នុងប្រភេទសញ្ជាតិឬសិទ្ធិស្នាក់នៅដែលបានរៀបរាប់ខាងលើទេមានតែគ្រួសារដែលស្ថិតក្នុងលក្ខខណ្ឌណាមួយខាងក្រោមប៉ុណ្ណោះ ដែលអាចទទួលបានប្រាក់ឧបត្ថម្ភនេះ① គ្រួសារដែលកំពុងទទួលបានជំនួយសង្គមសម្រាប់ការរស់នៅ (生活保護世帯)។
② គ្រួសារដែលមិនជាប់ពន្ធលើប្រាក់ចំណូលរបស់ប្រជាពលរដ្ឋក្នុងតំបន់ (住民税非課税世帯)។

<u>សញ្ជាតិ / ស្ថានភាពស្នាក់នៅ</u>
(1) សញ្ជាតិជប៉ុន (2) អ្នកស្នាក់នៅអចិន្ត្រៃយ៍ពិសេស (3) អ្នកស្នាក់នៅអចិន្ត្រៃយ៍ (4) ប្តីប្រពន្ធឬកូនរបស់ជនជាតិជប៉ុន
(5) ប្តីប្រពន្ធឬកូនរបស់អ្នកស្នាក់នៅអចិន្ត្រៃយ៍
(6) អ្នកស្នាក់នៅរយៈពេលវែងដែលត្រូវបានទទួលស្គាល់ថាមានបំណងរស់នៅជប៉ុនជាអចិន្ត្រៃយ៍
(7) អ្នកមានស្ថានភាព «ស្នាក់នៅជាមួយគ្រួសារ» ដែលបានបញ្ចប់បឋមសិក្សានិងអនុវិទ្យាល័យនៅជប៉ុនហើយ ត្រូវបានទទួលស្គាល់ថាមានបំណងធ្វើការនិងតាំងទីលំនៅនៅជប៉ុនក្រោយវិទ្យាល័យ

ព័ត៌មានលម្អិតនិងទម្រង់ពាក្យស្នើសុំមាននៅលើគេហទំព័រខេត្តឬនៅការិយាល័យសាលា។
គេហទំព័រខេត្ត: https://www.pref.kanagawa.jp/docs/en7/cnt/f531013/

ថ្ងៃផុតកំណត់៖ថ្ងៃអង្គារទី 15 ខែធ្នូឆ្នាំ 2026

ទំនាក់ទំនង៖ការិយាល័យសាលាឬក្រុមប្រឹក្សាអប់រំកាណាហ្គាវ៉ា ផ្នែកហិរញ្ញវត្ថុ

សន្លឹកពិនិត្យលក្ខខណ្ឌដើម្បីដឹងថា លោកអ្នកអាចទទួលបានប្រាក់ឧបត្ថម្ភការសិក្សាប្រភេទណា

Q1 គិតត្រឹមថ្ងៃទី1 ខែកក្កដា ឆ្នាំ2026
តើអាណាព្យាបាលរបស់សិស្សមានទីលំនៅក្នុងខេត្តកាណាហ្គាវ៉ាដែរឬទេ?

ទេ → សូមទាក់ទងទៅកាន់ស្ថាប័នរដ្ឋបាលនៃតំបន់ (都道府県) ដែលលោកអ្នករស់នៅ ដើម្បីសាកសួរព័ត៌មានបន្ថែម។

មែន ↓

Q2 តើសិស្សកំពុងរៀននៅវិទ្យាល័យ ឬសាលាដែលមានកម្រិតស្មើនឹងវិទ្យាល័យ គិតត្រឹមថ្ងៃទី1 ខែកក្កដា ឆ្នាំ2026 ដែរឬទេ?

ទេ → មិនមានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភ

មែន ↓

Q3 តើលោកអ្នកស្ថិតក្នុងប្រភេទណាមួយក្នុងចំណោមប្រភេទ (1) ដល់ (7) ខាងក្រោមដែរឬទេ?

(1) អ្នកដែលមានសញ្ជាតិជប៉ុន (2) អ្នកដែលមានសិទ្ធិស្នាក់នៅអចិន្ត្រៃយ៍ពិសេស (3) អ្នកដែលមានសិទ្ធិស្នាក់នៅអចិន្ត្រៃយ៍ (4) អ្នកដែលមានស្ថានភាពស្នាក់នៅជាប្តីប្រពន្ធ ឬកូនរបស់ជនជាតិជប៉ុនជាដើម (5) អ្នកដែលមានស្ថានភាពស្នាក់នៅជាប្តីប្រពន្ធឬកូនរបស់អ្នកមានសិទ្ធិស្នាក់នៅអចិន្ត្រៃយ៍ជាដើម
(6) ក្នុងចំណោមអ្នកដែលមានស្ថានភាពស្នាក់នៅរយៈពេលវែងកដែលត្រូវបានទទួលស្គាល់ថាមានបំណងរស់នៅជាអចិន្ត្រៃយ៍ក្នុងប្រទេសជប៉ុននាពេលអនាគត។
(7) ក្នុងចំណោមអ្នកដែលមានស្ថានភាពស្នាក់នៅជាសមាជិកគ្រួសារអ្នកដែលបានបញ្ចប់ការសិក្សានៅសាលាបឋមសិក្សានិងអនុវិទ្យាល័យក្នុងប្រទេសជប៉ុនហើយត្រូវបានទទួលស្គាល់ថាមានបំណងធ្វើការ និងរស់នៅជាប្រចាំក្នុងប្រទេសជប៉ុនបន្ទាប់ពីបញ្ចប់ការសិក្សានៅវិទ្យាល័យ ឬគ្រឹះស្ថានអប់រំដែលមានលក្ខណៈសមមូល។

មែន ↓

ទេ ↓

Q4 តើចាប់ផ្តើមរៀនវិទ្យាល័យ ក្រោយខែមេសា 2026 ទេ?

មែន → Q5 តើស្ថានភាពស្នាក់នៅរបស់សិស្សក្នុងប្រទេសជប៉ុន ជាប្រភេទ «留学»ដែរឬទេ?

មែន → មិនមានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភ

ទេ ↓

Q6 តើលោកអ្នកស្ថិតក្នុងប្រភេទណាមួយក្នុងចំណោមប្រភេទ (1)–(3) ខាងក្រោមដែរឬទេ?

(1) គិតត្រឹមថ្ងៃទី1ខែកក្កដាឆ្នាំ2026ជាគ្រួសារដែលកំពុងទទួលបានជំនួយសម្រាប់ការប្រកបរបរចិញ្ចឹមជីវិតក្រោមប្រព័ន្ធជំនួយសង្គម ។
(2) គ្រួសារដែលចំនួនសរុបនៃពន្ធលើប្រាក់ចំណូលក្នុងពន្ធប្រជាពលរដ្ឋរបស់អាណាព្យាបាលទាំងអស់សម្រាប់ឆ្នាំសារពើពន្ធ2026 ស្មើនឹង 0 យ៉ែន (មិនជាប់ពន្ធ)។
(3) គ្រួសារដែលចំនួនសរុបនៃពន្ធលើប្រាក់ចំណូលក្នុងពន្ធប្រជាពលរដ្ឋរបស់អាណាព្យាបាលទាំងអស់សម្រាប់ឆ្នាំសារពើពន្ធ2026 មានចំនួនតិចជាង 182,500 យ៉ែន។

※ ប្រសិនបើអ្នកបានឆ្លើយថា «ទេ» នៅសំណួរទី៣ (Q3) ហើយបន្តតាមសំណួរទី៤ (Q4) ឬសំណួរទី៥ (Q5) រហូតដល់សំណួរទី៦ (Q6) អ្នកត្រូវពិនិត្យតែលក្ខខណ្ឌ (1) ឬ (2) ប៉ុណ្ណោះ។
ប្រសិនបើគ្រួសាររបស់អ្នកបំពេញលក្ខខណ្ឌ (1) ឬ (2) សូមឆ្លើយថា «បាទ/ចាស»។
ប៉ុន្តែ ប្រសិនបើគ្រួសាររបស់អ្នកបំពេញតែលក្ខខណ្ឌ (3) ហើយមិនបំពេញលក្ខខណ្ឌ (1) ឬ (2) ទេ សូមឆ្លើយថា «ទេ»។

មែន ↓

ទេ → មិនមានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភ

មានសិទ្ធិទទួលប្រាក់អាហារូបករណ៍

ក្នុងករណី (1)
①គ្រួសារដែលកំពុងទទួលបានជំនួយសង្គមសម្រាប់ការរស់នៅ

ក្នុងករណី(2)
②គ្រួសារដែលមិនជាប់ពន្ធលើប្រាក់ចំណូលរបស់ប្រជាពលរដ្ឋក្នុងតំបន់

ក្នុងករណី(3)
ហើយចំនួនសរុបនៃពន្ធលើប្រាក់ចំណូលក្នុងពន្ធប្រជាពលរដ្ឋ ចំនួនតិចជាង 105,500 យ៉ែន។
③គ្រួសារដែលមានប្រាក់ចំណូលប្រចាំឆ្នាំប្រហែល 2,700,000 ដល់ 3,800,000 យ៉ែន

ក្នុងករណី (3)
ដែលចំនួនទឹកប្រាក់ពន្ធសរុបគិតតាមប្រាក់ចំណូល (所得割) មានចំនួនតិចជាង 182,500 យ៉ែន
④ គ្រួសារដែលមានប្រាក់ចំណូលប្រចាំឆ្នាំប្រហែលពី 3,800,000 យ៉ែន ដល់ 4,900,000 យ៉ែន។

កូដ QR ទម្រង់ដាក់ពាក្យ

បើមកដល់ «មានសិទ្ធិទទួលប្រាក់អាហារូបករណ៍» ខាងលើអាចដាក់ពាក្យបាន។
សាលាខេត្តកាណាហ្គាវ៉ា៖សូមដាក់ពាក្យតាមអនឡាញ (URL ឬកូដ QR ខាងក្រោម)។
URL：https://dshinsei.e-kanagawa.lg.jp/140007-u/offer/offerList_detail?tempSeq=129976
សាលាផ្សេង៖សូមទាញយកទម្រង់ពីគេហទំព័រខេត្តហើយដាក់នៅការិយាល័យសាលា។